E11/48

**ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា**
#១២ ផ្លូវ២៨២ ភ្នំពេញ កម្ពុជា

**ជំនួយផ្នែកច្បាប់នៃកម្ពុជា**

ដាក់ជូនទៅ: អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
លេខសំណុំរឿង: 002/19-09-2007-ECCC/PTC
កាលបរិច្ឆេទដាក់ជូន: ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨
អ្នកដាក់ពាក្យបណ្ដឹង: មេធាវីរបស់ភាគីបណ្ដឹងរដ្ឋប្បវេណី
ភាសាដើម: ភាសាអង់គ្លេស
ប្រភេទឯកសារ: សាធារណៈ

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 19 / 03 / 2008
ម៉ោង (Time/Heure): 15h50 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

**សារណាច្បាប់**

**សារណារួមតបទៅនឹងសារណារបស់មេធាវីការពារក្ដី សហព្រះរាជអាជ្ញា និងសារណាសាធារណៈ:ទាក់ទងនឹងការចូលរួមពីភាគីបណ្ដឹងរដ្ឋប្បវេណីក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន**

**រៀបចំឡើងដោយ:**
មេធាវីរបស់ភាគីបណ្ដឹងរដ្ឋប្បវេណី
មេធាវី ហុង គីមសួន
មេធាវី យុង ផានិត
មេធាវី ឡោ ជុនធី
មេធាវី នី ចាន់ឌី

**ផ្ញើរជូន:**
ចៅក្រមនៃអង្គបុរេជំនុំជម្រះ
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម រ៉ូវ៉ាន់ ដោននីង
ចៅក្រម ន័យ ថុល
ចៅក្រម ខាទីនខា ឡាហ៊ូស
ចៅក្រម ហួត វុទ្ធី
ចៅក្រម ប៉ែន ពេជ សាលី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

Original EN: 00165921-00165930

C11/48

**មេធាវីការពារក្តី**

**សហមេធាវីរបស់នួន ជា**

មេធាវី ស៊ុន អារុណ

មេធាវី Michiel Pestman

មេធាវី Victor Koppe

**សហមេធាវីរបស់អៀងសារី**

មេធាវី អាង ឧត្តម

មេធាវី Michael Karnavas

**សហមេធាវី និងទីប្រឹក្សាច្បាប់របស់អៀងធីរិទ្ធ**

មេធាវី Phat Pouvseang

ទីប្រឹក្សាច្បាប់ Diana Ellis QC

**សហមេធាវីរបស់លោក ខៀវ សំផន**

មេធាវី សាយ បូរី

មេធាវី Jacques Vergès

**សហព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញា ជា លាង

ព្រះរាជអាជ្ញា រ៉ូប៊ឺត ពេទីត

## I. ប្រវត្តិនីតិវិធី

1. ផ្អែកលើវិធាន២៣នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក ជនរងគ្រោះត្រូវបានគេទទួលស្គាល់ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿងក្តីប្រឆាំងនឹង នួន ជា នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ ហើយទទួលបានសេចក្តីជូនដំណឹងនេះនៅថ្ងៃសុក្រ ទី១ ខែកុម្ភៈ ឆ្នាំ២០០៨។ ដោយសារខ្វះពេលវេលា[1] ក្រឡាបញ្ជីពុំបានជូនដំណឹងដល់តំណាងផ្នែកច្បាប់ អំពីសវនាការនៅថ្ងៃច័ន្ទ ទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ទេ។ អង្គបុរេជំនុំជម្រះពុំបានអញ្ជើញតំណាងផ្នែកច្បាប់នៃភាគីដើមបណ្តឹងរដ្ឋប្បវេណីឱ្យដាក់សារណា ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០០៨ទេ[2] ពីព្រោះតំណាងផ្នែកច្បាប់ទាំងនោះពុំទាន់ត្រូវបានទទួលការតែងតាំងជាមេធាវីរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅឡើយ ហើយគេក៏ពុំបានស្នើសុំឱ្យតំណាងផ្នែកច្បាប់ទាំងនោះដាក់សារណាជាលាយលក្ខណ៍អក្សរ ចាប់តាំងពីខ្លួនបានទទួលការតែងតាំងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨។
2. អង្គបុរេជំនុំជម្រះបានបើកសវនាការនៅថ្ងៃទី៧-៨ ខែកុម្ភៈ ឆ្នាំ២០០៨ លើបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយសហមេធាវីរបស់ជនជាប់ចោទ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត។
3. នៅឯសវនាការ និងក្នុងសារណារបស់ខ្លួន មេធាវីបានជំទាស់ថា ការចូលរួមពីភាគីរដ្ឋប្បវេណីក្នុងសវនាការបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន នឹងរំលោភសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ គេជំទាស់ថា ភាគីរដ្ឋប្បវេណីពុំបានដាក់សារណារបស់ខ្លួនជាលាយលក្ខណ៍អក្សរ ព្រមទាំងពុំបានបង្ហាញពីផលប្រយោជន៍ផ្ទាល់ក្នុងការចូលរួមនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។ លើសពីនេះទៅទៀត មេធាវីជំទាស់ថា វិធាន២៣នៃវិធានផ្ទៃក្នុងមិនផ្តល់សិទ្ធិដល់ភាគីរដ្ឋប្បវេណីក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនទេ។ ពួកគេបាន

---

[1] នៅពេលនោះ អង្គភាពជនរងគ្រោះ មិនអាចជួយអ្វីដោយប្រសិទ្ធភាពដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងលក្ខណៈសមស្របណាមួយ បាននៅឡើយ ហើយក៏មិនអាចផ្តល់នូវតំណាងផ្នែកច្បាប់ឱ្យភាគីដើម្បីបណ្តឹងរដ្ឋប្បវេណីបានដែរ។ មូលនិធិសម្រាប់តំណាងផ្នែកច្បាប់នៃភាគីដើមបណ្តឹងរដ្ឋប្បវេណីក្រីក្រ - ផ្ទុយទៅនឹងមេធាវីការពារក្តី - គេពុំអាចដឹងជាមុនបានទេ នៅក្នុងថវិការបស់អ.វ.ត.ក។

[2] សូមអានសារណារបស់មេធាវីការពារក្តី កថាខណ្ឌ៥។

និយាយដល់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះឧទ្ធរណ៍ នៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (“ICC”) ក្នុងសំណុំរឿងក្ដី *ព្រះរាជអាជ្ញា ទល់នឹង Thomas Lubanga Dyilo* ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧។

4. អង្គបុរេជំនុំជម្រះបានចេញសេចក្ដីជូនដំណឹងមួយនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៨ ហើយបានស្នើសុំភាគីរដ្ឋប្បវេណីដាក់សារណាអំពីបញ្ហានៃការចូលរួម ពីភាគីរដ្ឋប្បវេណីក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន និងបានស្នើសុំឱ្យ*អ្នកធ្វើសារណា* ថ្លឹងថ្លែងបញ្ហាតុល្យភាពរវាងសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិរបស់ភាគីរដ្ឋប្បវេណី ក្នុងបរិបទវិធានផ្ទៃក្នុងរបស់អ.វ.ត.ក រហូតដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨។ ភាគីទាំងឡាយមានឱកាសក្នុងការឆ្លើយតបទៅនឹងសារណានានារហូត ដល់ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០៨។

5. តំណាងផ្នែកច្បាប់ដាក់ជូនសារណារួមមួយឆ្លើយតប ជាពិសេសទៅនឹងសារណារបស់មេធាវីការពារក្ដី សហព្រះរាជអាជ្ញា និងអ្នកធ្វើសារណាសាធារណៈ Anne Heindel និង Christoph Safferling។

## II. ប្រភពច្បាប់

6. អនុលោមតាមច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក[3] ក្នុងមាត្រា២០(ថ្មី) និងមាត្រា២២(ថ្មី) និងមាត្រា១២ នៃកិច្ចព្រមព្រៀង[4] ច្បាប់ដែលអាចអនុវត្តបានគឺច្បាប់ជាតិរបស់កម្ពុជា។ ប្រសិនបើនីតិវិធីជាធរមានទាំងនេះមិនអាចដោះស្រាយបញ្ហាពិសេសណាមួយបាន ឬប្រសិនបើមានភាពមិនប្រក្រតីទាក់ទងនឹងការបកស្រាយ ឬការអនុវត្តរបស់ខ្លួន ឬប្រសិនបើមានបញ្ហាណាមួយទាក់ទងនឹងភាពសមស្របជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ វិធានផ្ទៃក្នុងជាអ្នកបង្រួបបង្រួមនីតិវិធីដែលអាចអនុវត្តបានរបស់កម្ពុជា នៅចំពោះមុខអ.វ.ត.ក[5]។

---

[3] ច្បាប់ស្ដីពីការបង្កើតអ.វ.ត.ក ដែលបានធ្វើការកែប្រែនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (NS/SRK/1004/006)

[4] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋទាំងឡាយ ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣។

[5] សូមអានបុព្វកថានៃវិធានផ្ទៃក្នុង។

7. ប៉ុន្តែ ប្រសិនបើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានភាពច្បាស់លាស់ មិនស្រពិចស្រពិល ទាក់ទងនឹងការបកស្រាយ ទាក់ទងនឹងបញ្ហាពិសេសណាមួយដែលកំពុងចោទលើកឡើងហើយស៊ីគ្នាជាមួយបទដ្ឋានអន្តរជាតិ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានអាទិភាពលើវិធានផ្ទៃក្នុង។

8. ដូច្នេះ ទាក់ទងនឹងបញ្ហាដែលបានលើកឡើងអំពី:

(១) ការចូលរួមពីភាគីរដ្ឋប្បវេណី

(២) ផលប្រយោជន៍ផ្ទាល់របស់ភាគីរដ្ឋប្បវេណីក្នុងបណ្តឹងឧទ្ធរណ៍

(៣) ការកំហិតដែនកំណត់នៃការចូលរួមពីភាគីរដ្ឋប្បវេណី

ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគឺជាប្រភពទីមួយ ក្នុងការផ្តល់ចំលើយអំពីលក្ខណ:នៃសិទ្ធិរបស់ភាគីរដ្ឋប្បវេណី និងការអនុវត្តនៅចំពោះអ.វ.ត.ក។

ប្រសិនបើ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ស្របគ្នាជាមួយនឹងលក្ខខណ្ឌនានាដូចបាននិយាយខាងលើ (*ចូរមើលកថាខណ្ឌ៦*) វាជាច្បាប់ដែលអាចអនុវត្តបាន (lex specialis)។ ក្នុងករណីមានលក្ខណ:ផ្ទុយគ្នារវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគឺជាច្បាប់អាចចងបាន។

## III. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងការចូលរួមពីភាគីរដ្ឋប្បវេណីក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួន

9. មេធាវីនិយាយថា[6] យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ការចូលរួមបែបនេះក្នុងបណ្តឹងឧទ្ធរណ៍គឺ "*ត្រូវហាមឃាត់ជាដាច់ខាត* "។ មេធាវីនិយាយយោងដល់មាត្រា២នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ហើយជំទាស់ថា "*បណ្តឹងរដ្ឋប្បវេណី និងបណ្តឹងព្រហ្មទណ្ឌគឺជាបណ្តឹងដាច់ដោយឡែកពីគ្នា បណ្តឹងរដ្ឋប្បវេណីមានបំណងទាមទារសំណង និងសំណងខូចខាត ហើយបណ្តឹងអាជ្ញារបស់ព្រះរាជអាជ្ញាធ្វើឡើងក្នុងគោលបំណងប្រយោជន៍ទូទៅ*"។ ហេតុដូច្នេះ មេធាវីយល់ឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាអនុញ្ញាតឱ្យបានតែ "*បណ្តឹងសុំតាំងខ្លួនជាភាគីរដ្ឋប្បវេណី* " មានទិសដៅតែចំពោះសំណង និងលទ្ធភាពនៃការចូលរួមបន្ទាប់ពីតុលាការព្រហ្មទណ្ឌមួយបានប្រកាសថា ជនជាប់ចោទមានពិរុទ្ធ។

---

[6] សូមអានកថាខណ្ឌ២ ៨ ១០ នៃសារណារបស់មេធាវី។

10. លើសពីនេះទៅទៀត មេធាវីបន្តថា បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនដែលកំពុងរងចាំការសម្រេចនោះត្រូវរក្សាទុកសម្រាប់ព្រះរាជអាជ្ញានិងជនជាប់ចោទ មិនមែនសម្រាប់ភាគីរដ្ឋប្បវេណីទេ។ ពីព្រោះការចូលរួមពីភាគីរដ្ឋប្បវេណីពុំមាននិយាយក្នុងសវនាការតទល់គ្នា[7] ទាក់ទងនឹងការចេញដីកាឃុំខ្លួនទេ មេធាវីជំទាស់ថា ការចូលរួមពីភាគីរដ្ឋប្បវេណីពុំត្រូវគេអនុញ្ញាតឱ្យក្នុងបណ្តឹងឧទ្ធរណ៍ដែលកំពុងរងចាំការសម្រេចទេ យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។

11. មេធាវីត្រូវតែបរាជ័យក្នុងអំណះអំណាងទាំងនេះ។

ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[8] ចែងក្នុងមាត្រា៥ដូចខាងក្រោម:

> *"បង្កើតឱមានសកម្មភាពបណ្តឹងអាជ្ញាធ្វើឡើងដោយជនរងគ្រោះ*
> *ជនរងគ្រោះនៃអំពើឧក្រិដ្ឋ ឬបទល្មើសមជ្ឈិម អាចដាក់ពាក្យបណ្តឹងក្នុងឋានៈជាដើមបណ្តឹង រដ្ឋប្បវេណីទៅចៅក្រមស៊ើបអង្កេត។ បណ្តឹងក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីជាការដាក់បណ្តឹងអាជ្ញាជូនដល់ចៅក្រមស៊ើបអង្កេត នៅក្នុងស្ថានភាពផ្សេងៗដូចមានចែងក្នុងមាត្រា១៣៩(...) និង១៤០(...)"។*

បើទោះជាអនុញ្ញាតិឱ្យជនរងគ្រោះធ្វើ "បណ្តឹងអាជ្ញា" និងចូលរួមជាភាគីរដ្ឋប្បវេណីបានក៏ដោយ ក៏វាបង្ហាញច្បាស់ថា ភាគីរដ្ឋប្បវេណីមិនត្រឹមតែឋិតក្នុងតួនាទីសកម្មមួយក្នុង "បណ្តឹងរដ្ឋប្បវេណី" ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចឋិតនៅក្នុង "បណ្តឹងអាជ្ញា" បានផងដែរ។ ហេតុដូច្នេះមិនថាឡើយ ព្រះរាជអាជ្ញាធ្វើ "បណ្តឹងអាជ្ញា" ឬជនរងគ្រោះធ្វើទេ ក៏គេអនុញ្ញាតិឱ្យជនរងគ្រោះចូលរួម "បណ្តឹងអាជ្ញា" ជាភាគីបណ្តឹងរដ្ឋប្បវេណីដែរ។

12. ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[9] ពិពណ៌នាអំពីដំណើរការប្រព្រឹត្តជាទូទៅនៃសវនាការលើបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គសភាស៊ើបអង្កេត *"La chambre d'instruction"* ដែលដំណើរការនេះដូចគ្នានឹងអង្គបុរេជំនុំជម្រះនៅចំពោះមុខអ.វ.ត.ក។ ក្នុងកិច្ចដំណើរការសវនាការលើបណ្តឹងឧទ្ធរណ៍ គ្មានភាពខុសគ្នារវាងបណ្តឹងឧទ្ធរណ៍ ដែលស្នើឡើងដោយភាគីរដ្ឋប្បវេណីឬមេធាវីចុងចោទទេ។

---

[7] សូមអានមាត្រា២០៦ ២៦៦-២៦៨។

[8] ដកស្រង់បន្ថែមជាភាសាបារាំង។

[9] សូមអានមាត្រា ២៥៧-២៦៥ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា

មាត្រា២៥៨ ចែងថា:

*"ដីកាជូនដំណឹងត្រូវបញ្ជូនទៅឱជនត្រូវចោទកំពុងជាប់ឃុំ ដូចតទៅ ដីកាជូនដំណឹងត្រូវបញ្ជូនទៅឱជនត្រូវចោទនៅក្រៅឃុំ ដើមបណ្តឹងរដ្ឋប្បវេណី និងទៅឱមេធាវី ដូចតទៅ*

មាត្រា២៥៩ ចែងដូចខាងក្រោម:

*"...អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍និងមេធាវីការពារក្តីអាចពិគ្រោះលើសំណុំរឿង រហូតដល់ពេលបើកសវនាការ។*

*អគ្គរដ្ឋអាជ្ញា **ត្រូវ**[10]ដាក់ជូនក្រឡាបញ្ជីនូវសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរយ៉ាងយូរបំផុតរហូតដល់មុនពេលបើកសវនាការមួយថ្ងៃ។*

*ភាគីនានា និងមេធាវីការពារក្តី **អាច**[11]ដាក់សារណារបស់គេជូនដល់ក្រឡាបញ្ជី។(...) ភាគីនានានិងមេធាវីការពារក្តីត្រូវបានអនុញ្ញាតឱបង្ហាញសារណារបស់ខ្លួនរហូតដល់ពេលចាប់ផ្តើមបើកសវនាការ"។*

មាត្រា២៦០ ចែងថា:

*"តាមរយៈរបាយការណ៏របស់ប្រធានអង្គចៅក្រមស៊ើបអង្កេតអគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍ និងមេធាវីធ្វើការសន្និដ្ឋានសង្ខេប(...)"។*

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[12] បញ្ជាក់ថា[13] អង្គសភាស៊ើបអង្កេតមានសមត្ថកិច្ចលើរាល់បណ្តឹងឧទ្ធរណ៍ទាំងអស់ក្នុងដំណាក់កាលដំបូង (ហើយមានទំនាក់ទំនងគ្នាជាមួយអង្គបុរេជំនុំជម្រះ) និងជូនដំណឹងអំពីកាលបរិច្ឆេទសវនាការដល់ភាគីទាំងឡាយ និងមេធាវីរបស់ពួកគេ។ លើសពីនេះទៀត ត្រូវកត់សំគាល់ថា *ភាគីទាំងឡាយ និងមេធាវី* អាចដាក់សេចក្តីថ្លែងជាលាយលក្ខណ៍អក្សរនៅចំពោះមុខសវនាការ ហើយអាចធ្វើសេចក្តីថ្លែងដោយផ្ទាល់មាត់ក្នុងអំឡុងពេលសវនាការបាន។

---

[10] មានបញ្ជាក់បន្ថែម

[11] សូមអានចំណុចទី៨ខាងលើ

[12] សូមអានមាត្រា២៥៧នៃក្រមនិតិវិធីព្រហ្មទណ្ឌ

[13] សូមអានមាត្រា២៥៨

13. មាត្រាពាក់ព័ន្ធ៥ និង២៥៨-២៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ជាមាត្រាដែលចែងយ៉ាងច្បាស់ មិនស្រពិចស្រពិលទាក់ទងនឹងការបកស្រាយ គ្មានភាពផ្ទុយគ្នា និងស៊ីសង្វាក់គ្នានឹងស្តង់ដារអន្តរជាតិ។ មាត្រាទាំងអស់នេះបំពេញលក្ខខណ្ឌចាំបាច់ ដែលបានលើកឡើងផ្នែកខាងដើម[14]។ ដូចនេះ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាប្រើប្រាស់ និងបញ្ជាក់សិទ្ធិក្នុងការចូលរួមរបស់រដ្ឋប្បវេណី និងតំណាងផ្នែកច្បាប់របស់ខ្លួន នៅក្នុងបញ្ហាកំពុងលើកឡើង។ លើសពីនេះទៀត ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាគោរពសិទ្ធិពេញលេញរបស់ជនត្រូវចោទ និងការចូលរួមរបស់ភាគីរដ្ឋប្បវេណី ក្នុងបណ្តឹងឧទ្ធរណ៍ជាទូទៅ និងដូចគ្នានេះដែរ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនមិនរំលោភសិទ្ធិរបស់ជនត្រូវចោទទេ[15]។ ហេតុដូចនេះ នៅពេល ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាអាចយកមកប្រើប្រាស់បាន គេមិនចាំបាច់យកវិធានផ្ទៃក្នុង[16] និងការអនុវត្តអន្តរជាតិមកការពិភាក្សាលើបញ្ហាកំពុងរងចាំការដោះស្រាយនោះទេ។

14. លើសពីនេះទៀត ផ្ទុយទៅនឹងទស្សនរបស់មេធាវី នៅកម្ពុជា ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសវនាការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការដីកាឃុំខ្លួន ត្រូវបានគេអនុវត្ត និងដឹងឮយ៉ាងទូលំទូលាយ[17]។

---

[14] សូមអានកថាខណ្ឌ៦

[15] ក្នុងប្រព័ន្ធច្បាប់ស៊ីវិលផ្សេងៗទៀត ភាគីរដ្ឋប្បវេណីក៏ទទួលបានសិទ្ធិពេញលេញ ជាភាគីក្នុងនិតិវិធីព្រហ្មទណ្ឌដែរ។ ការអនុវត្តសិទ្ធិដ៏ទូលំទូលាយបែបនេះមិនដែលបានត្រូវគេមើលឃើញថាជាបុរេវិនិច្ឆ័យចំពោះចុងចោទនោះទេ។ លើសពីនេះទៀត ដូចជារឿងក្តីរបស់ Perez v. France (សំណុំរឿងលេខ៤៧២៨៧/៩៩) តុលាការសិទ្ធិមនុស្សអឺរ៉ុប (CHRC) បានលើកឡើងថា:

"សិទ្ធិក្នុងការទទួលការកាត់ទោសដោយយុត្តិធម៏ត្រូវបានធានាដោយមាត្រា៦\១ របស់អនុសញ្ញាសហគមន៍អឺរ៉ុប នៃសិទ្ធិមនុស្ស រួមបញ្ចូលទាំងសិទ្ធិរបស់ភាគីដាក់សារណា ដែលគេគិតថាសារណាទាំងនោះមានសារសំខាន់សម្រាប់ការកាត់ក្តី"។

[16] សូមអានវិធាន៧៤ ៧៧(៣) និង៧៧(៤) ជាវិធានផ្ទៃក្នុងដែលមានខ្លឹមសារប្រហាក់ប្រហែលនឹងក្រមនិតិវិធីព្រហ្មទណ្ឌកម្ពុជា។

[17] សូមអានសំណុំរឿងលេខ១៧០ ប៊ិន សំណាង និងសុខ សំអឿន (ហៅប៊ឿន) ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៤ សាលាឧទ្ធរណ៍ ទីក្រុងភ្នំពេញ កម្ពុជា
សំណុំរឿងលេខ៦៩៦ ទាំង នី ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ សាលាឧទ្ធរណ៍ ទីក្រុងភ្នំពេញ កម្ពុជា ក្នុងករណីទាំង២ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់គាត់បានចូលរួមក្នុងសវនាការបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង ដីកាឃុំខ្លួន។

00172180

E11/48

## IV. ក្រមនីតិវិធីព្រហ្មទណ្ឌ និងលក្ខខណ្ឌនៃផលប្រយោជន៍បុគ្គល នៅក្នុងសវនាការបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួន

15. មេធាវីការពារក្ដីនិយាយយោង[18]ទៅដល់តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងជាពិសេសចំពោះរឿងក្ដី Thomas Lubanga Dyilo និងសំណូមពរសុំឱ្យមានការអនុវត្តប្រហាក់ប្រហែលគ្នាទៅនឹងការអនុវត្តនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ នៅពេលដែលជនរងគ្រោះត្រូវបង្ហាញពីផលប្រយោជន៍ផ្ទាល់ មុននឹងពួកគេទទួលការអនុញ្ញាតឱ្យចូលរួមក្នុងបណ្ដឹងឧទ្ធរណ៍នៃដីកាឃុំខ្លួន។

16. ការពឹងអាស្រ័យរបស់មេធាវីលើយុត្តិសាស្ត្ររបស់តុលការព្រហ្មទណ្ឌអន្តរជាតិក្នុងបញ្ហានេះជាការពឹងអាស្រ័យមិនត្រូវតាមកាលៈទេសៈ។ ដូចដែលបានលើកឡើងខាងដើមរួចហើយ[19] តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ជាច្បាប់ពាក់ព័ន្ធអាចប្រើបាន ដែលផ្ដល់ឱ្យជនរងគ្រោះនូវឋានៈជាភាគីរដ្ឋប្បវេណី និងការនិយាយទៀតថាតុលាការឧក្រិដ្ឋកម្មអន្តរជាតិទាក់ទងនឹងបញ្ហាលើកឡើងនេះមិនត្រូវបានបញ្ជាក់ទេ ពីព្រោះក្រមនីតិវិធីព្រហ្មទណ្ឌមានអាទិភាព និងអាចអនុវត្តបាន។ លើសពីនេះទៀត ក្រមនីតិវិធីព្រហ្មទណ្ឌមិនបានទាមទារពីជនរងគ្រោះឱ្យបង្ហាញផលប្រយោជន៍ផ្ទាល់ខ្លួន ក្នុងតំណាក់កាលនានា និងសវនាការទេ។ លើសពីនេះទៀត ជនរងគ្រោះ ដែលបានដាក់ពាក្យជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងដំណាក់កាលនៃការស៊ើបអង្កេតនឹងមិនចាំបាច់ដាក់ពាក្យបណ្ដឹងជាថ្មីម្ដងទៀតទេ[20]។

នៅពេលបានការយល់ព្រមឱ្យធ្វើជាភាគីរដ្ឋប្បវេណី ជនរងគ្រោះនិងតំណាងផ្នែកច្បាប់របស់ពួកគាត់អាចប្រើប្រាស់សិទ្ធិបានច្រើនយ៉ាងដូចជា ការពិនិត្យមើលសំណុំរឿង[21] ការចូលរួមក្នុងគ្រប់តំណាក់កាលនៃកិច្ចដំណើរការនីតិវិធី[22] បង្ហាញភស្តុតាង[23] និងសាកសួរសាក្សី[24]។

---

[18] សូមអានកថាខណ្ឌ១៤-១៨ និង២៤-២៦ ក្នុងសារណារបស់មេធាវីការពារក្ដី

[19] សូមអានកថាខណ្ឌ១៣

[20] សូមអានវិធាន២៣(៤) វិធានផ្ទៃក្នុង

[21] សូមអានវិធាន៥៦(១១) និងកថាខណ្ឌ៨៦ វិធានផ្ទៃក្នុង

[22] សូមអានវិធាន២៣ វិធានផ្ទៃក្នុង

[23] សូមអានវិធាន៥៥(១០) វិធានផ្ទៃក្នុង

[24] សូមអានវិធាន៩១(២) វិធានផ្ទៃក្នុង

00172181

C11/48

មានតែនៅក្នុងពាក្យរបស់គាត់ប៉ុណ្ណោះដែលភាគីរដ្ឋប្បវេណីត្រូវបញ្ជាក់ថាពួកគាត់ជាជនរងគ្រោះ និងថាតើការឈឺចាប់របស់គាត់ពាក់ព័ន្ធយ៉ាងណានឹងរឿងក្តី[25]។

លក្ខខណ្ឌចាំបាច់បន្ថែមផ្សេងៗទៀតក្នុងដំណាក់កាលនានា និងសវនាការមិនចាំបាច់ទេ ទាំងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុង។

17. នៅក្រោមលក្ខន្តិកៈក្រុងរ៉ូម តុលាការឧក្រិដ្ឋកម្មអន្តរជាតិបានផ្តល់ឱ្យជនរងគ្រោះនូវឋានៈជា "អ្នកចូលរួម" នៅក្នុងកិច្ចដំណើរការនីតិវិធី ហើយអ្នកចូលរួមទាំងនេះបានទទួលសិទ្ធិក្នុងការបង្ហាញ "ទស្សនៈនិងការព្រួយបារម្ភ" នៅអំឡុងពេលដំណើរការនីតិវិធី[26]។ ប៉ុន្តែអ.វ.ត.ក ដែលយកតាមច្បាប់កម្ពុជាក្នុងប្រព័ន្ធច្បាប់ស៊ីវិល អនុញ្ញាតឱ្យជនរងគ្រោះចូលរួមជាភាគីបណ្តឹង ដោយទទួលបានសិទ្ធិចូលរួមដោយពេញលេញ[27]។

ដោយហេតុនេះ សិទ្ធិជនរងគ្រោះនៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិមត្រូវបានគេដាក់កំហិតឱ្យគ្រាន់តែជាអ្នកចូលរួម ហើយជាយថាផល ត្រូវបានប្រមូលចងក្រងសិទ្ធិទាំងនេះនៅក្នុងលក្ខន្តិកៈក្រុងរ៉ូម[28] និងនៅក្នុងវិធាននៃនីតិវិធីដំណើរការ និងភស្តុតាង។

តួនាទីរបស់ជនរងគ្រោះក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ មិនអាចយកមកអនុវត្តន៍ក្នុង អ.វ.ត.ក បានទេ។ មានន័យថា ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអ.វ.ត.ក មិនត្រូវបានគេសុំឱ្យដាក់សារណាបង្ហាញផលប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីឱ្យពួកគេអាចទទួលបានសិទ្ធិចូលរួមក្នុងដំណាក់កាលផ្សេងៗនៃកិច្ចដំណើរការនីតិវិធីទេ។

## V. ការដាក់កំហិតដែលអាចមានសក្តានុពលលើវិសាលភាពនៃសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី

---

[25] សូមអានវិធាន២៣(៥) វិធានផ្ទៃក្នុង

[26] លក្ខន្តិកៈក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៦៨(៣) "ការការពារជនរងគ្រោះ និងសាក្សី និងការចូលរួមរបស់ពួកគាត់ក្នុងកិច្ចដំណើរការនិតិវិធី"

[27] សូមមើលវិធាន ២៣ ២៤ ៣១(១) ៥៥ ៥៩ ៧២ ៧៤(៤) ៧៥ ៨៦ ៨៨ ៩៤ ៩៨(១) ១០០ ១០៣ ១០៥ ១១៣(១) នៃវិធានផ្ទៃក្នុង ក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលនិយាយពិស្តារអំពីសិទ្ធិចូលរួមក្នុងនិតិវិធី ដែលផ្តល់ឱ្យភាគីដើមបណ្តឹងរដ្ឋប្បវេណី នៅអ.វ.ត.ក។

[28] មាត្រា៦៨(៣) ដែលបានលើកឡើងពី "ផលប្រយោជន៍ផ្ទាល់ខ្លួន" ជាលក្ខខណ្ឌចាំបាច់

00172182

C11/48

18. ដូចមានក្នុងសារណាសាធារណៈ[29]របស់ Anne Heindel ចំណុចសំខាន់ដែលបានលើកឡើង គឺថា នៅពេលមេធាវីការពារក្តី និយាយជាទូទៅ[30] និងព្រះរាជអាជ្ញា និយាយដោយឡែក[31] សំណូមពរធ្វើនិយតកម្មនៃការចូលរួមរបស់ជនរងគ្រោះ ការដាក់កំហិតទាំងអស់ត្រូវៈ

(i) ស្របទៅនឹងច្បាប់ជាធរមាន

(ii) មានសមភាពជាមួយនឹងភាគីដទៃទៀត

(iii) មិនធ្វើឱ្យប៉ះពាល់សិទ្ធិរបស់ភាគីរដ្ឋប្បវេណីផ្សេងទៀត

19. យោបល់ឱ្យដាក់សារណាលាយលក្ខណ៍អក្សរ ដូចដែល Anne Heindel និងសហព្រះរាជអាជ្ញាទាមទារ បន្ថែមលើសំណើបដិសេធន៍សិទ្ធិបង្ហាញទឡ្ហីករណ៍ផ្ទាល់មាត់ ក្នុងករណីមិនបានដាក់សារណាជាលាយលក្ខណ៍អក្សរ មិនស៊ីសង្វាក់គ្នាជាមួយនឹងក្រមនីតិវិធីព្រហ្មទណ្ឌទេ។

20. ក្រមនីតិវិធីព្រហ្មទណ្ឌមិនមានចែងអំពីការដាក់សារណាជាលាយលក្ខណ៍អក្សរពីភាគី មុនពេលសវនាការបណ្តឹងឧទ្ធរណ៍ទេ។ ដូចបានរៀបរាប់ខាងដើមរួចហើយ[32] ក្រមនីតិវិធីព្រហ្មទណ្ឌបានលើកឡើងក្នុងមាត្រា២៥៩ថា ព្រះរាជអាជ្ញា***ត្រូវតែ***ដាក់សារណាជាលាយលក្ខណ៍អក្សរ ហើយថាភាគីដទៃទៀត***ក៏អាច***ធ្វើដូចគ្នាបានដែរ។

ជាក់ស្តែង ក្រមនីតិវិធីព្រហ្មទណ្ឌផ្តល់ឱ្យភាគីនូវសិទ្ធិបង្ហាញផ្ទាល់មាត់ក្នុងសវនាការបណ្តឹងឧទ្ធរណ៍[33] ហើយមិនបានដាក់លក្ខខណ្ឌចាំបាច់អ្វីត្រូវបំពេញនោះទេ។

21. ក្រមនីតិវិធីព្រហ្មទណ្ឌស៊ីសង្វាក់គ្នា និងច្បាស់ណាស់ត្រង់ចំណុចនេះ និងមិនមានចំណុចផ្ទុយគ្នាទេ។ ដូចនេះ ដូចដែលបានពន្យល់នៅខាងលើរួចហើយ[34] ច្បាប់កម្ពុជាជាធរមាន ក្រមនីតិវិធីព្រហ្មទណ្ឌ ជាច្បាប់ដែលអាចអនុវត្ត និងពាក់ព័ន្ធទៅនឹងបញ្ហាលើកឡើង។ អាស្រ័យហេតុនេះ សំណើរបស់ព្រះរាជអាជ្ញាទៅអង្គបុរេជំនុំជម្រះ ដើម្បីបង្គាប់ភាគីបណ្តឹងរដ្ឋប្បវេណីឱ្យដាក់សារណាជាលាយលក្ខណ៍អក្សរឱ្យបានមុន និងប្រសិនបើមិនបានដាក់

---

[29] សូមមើលកថាខណ្ឌ១៥-២៣

[30] សូមអានសារណារបស់មេធាវី កថាខណ្ឌ២៧-៣០

[31] សូមអានសារណារបស់ព្រះរាជអាជ្ញា កថាខណ្ឌ២២

[32] សូមអានកថាខណ្ឌ១២

[33] មាត្រា២៦០ ក្រមនិតិវិធីព្រហ្មទណ្ឌ

[34] សូមអានកថាខណ្ឌ៦

សារណាទេ ឱ្យបដិសេធន៍សិទ្ធិបង្ហាញទទ្បីករណ៍ផ្ទាល់មាត់ មិនស៊ីសង្វាក់គ្នានឹងក្រមនីតិវិធីព្រហ្មទណ្ឌទេ ហើយថែមទាំងធ្វើឱ្យប៉ះពាល់សិទ្ធិនៃការចូលរួមទៀតផង។

22. ទោះបីជាវិធានផ្ទៃក្នុង[35]បានចែងថាភាគីទាំងអស់*ត្រូវ*ដាក់សារណាជាលាយលក្ខណ៍អក្សរមុនសវនាការបណ្ដឹងឧទ្ធរណ៍ តាមការណែនាំរបស់វិធានផ្ទៃក្នុង ភាគីមានសិទ្ធិធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេបក្នុងអំឡុងពេលសវនាការ[36]។

វិធានពាក់ព័ន្ធមានភាពខុសគ្នារវាងពាក្យ "សេចក្ដីសន្និដ្ឋានដោយសង្ខេប" និង "សារណា" ដូចនេះ ភាគីបានទទួលការអនុញ្ញាតឱ្យធ្វើសេចក្ដីសន្និដ្ឋានដោយសង្ខេប ហើយសិទ្ធិធ្វើ "*សេចក្ដីសន្និដ្ឋានដោយសង្ខេប*" មិនត្រូវបានប៉ះពាល់ទេ បើទោះបីជាពួកគេមិនបានដាក់សារណាជាលាយលក្ខណ៍អក្សរមុនសវនាការក៏ដោយ។

ទាក់ទងទៅនឹងការខ្វះខាតសារណាជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងសវនាការបណ្ដឹងឧទ្ធរណ៍ និងការហាមប្រាមមិនឱ្យមានការបង្ហាញផ្ទាល់មាត់ មិនស៊ីសង្វាក់នឹងវិធានផ្ទៃក្នុងទេ។ វាធ្វើឱ្យប៉ះពាល់សិទ្ធិរបស់ភាគីដើមបណ្ដឹងរដ្ឋប្បវេណី និងធ្វើឱ្យសិទ្ធិនៃការចូលរួមមិនមានអត្ថន័យអ្វីទេ។

23. សហព្រះរាជអាជ្ញាស្នើទៅអង្គបុរេជំនុំជម្រះ "*ឱ្យបដិសេធន៍សិទ្ធិផ្ដល់ទទ្បីករណ៍ផ្ទាល់មាត់របស់ភាគីរដ្ឋប្បវេណី ដែល (...) គ្មានសារណាពាក់ព័ន្ធចំពោះរឿងក្ដីណាមួយនៃភាគីបណ្ដឹងឧទ្ធរណ៍*" គឺជាការដាក់កំហិត និងរំលោភបំពានសិទ្ធិរបស់ភាគីរដ្ឋប្បវេណី ដែលការធ្វើបែបនេះអាចប៉ះពាល់សិទ្ធិក្នុងការចូលរួមដើម្បីធានាដំណើរការសមស្រប តាមច្បាប់[37]។

---

[35] វិធាន៧៧(៤) វិធានផ្ទៃក្នុង

[36] វិធាន៧៧(១០) វិធានផ្ទៃក្នុង

[37] សូមអានរឿងក្ដីរបស់ Perez v. France នៃតុលាការសិទ្ធិមនុស្សអឺរ៉ុប (សំណុំរឿងលេខ ៤៧២៨៧/៩៩) ដែលតុលាការនោះបានលើកឡើងមាត្រា៦.១ នៃអនុសញ្ញា: "គោលបំណងនៃអនុសញ្ញាគឺធានាសិទ្ធិ ដែលសិទ្ធិនោះមិនមែនជាសិទ្ធិទ្រឹស្ដី ឬស្រមើស្រម៉ៃនោះទេ ប៉ុន្តែវាជាសិទ្ធិជាក់ស្ដែង និងមានប្រសិទ្ធភាព ប្រសិនបើការសន្និដ្ឋានត្រូវបានគេស្ដាប់នោះ" (...)។ ឬនិយាយម្យ៉ាងទៀតថា ឥទ្ធិពលមាត្រា៦ នៃអនុសញ្ញាគឺដាក់ឱ្យ "តុលាការ" មានភារកិច្ចពិនិត្យឱ្យបានត្រឹមត្រូវនូវរាល់សារណា ទទ្បីករណ៍ និងភស្ដុតាង ដែលភាគីនានាបានដាក់ និងដោយគ្មានបុរេវិនិច្ឆ័យវាយតម្លៃថាតើសារណា ទទ្បីករណ៍ និងភស្ដុតាងទាំងនោះពាក់ព័ន្ធ ឬមិនពាក់ពន្ធ័នឹងរឿងក្ដីទេ" (កថាខណ្ឌ៨០)។

C11/48

24. តំណាងផ្នែកច្បាប់ និងភាគីរដ្ឋប្បវេណីចង់ឱ្យមានការកាត់ទោសឆាប់ៗ និងចង់ផ្តល់នូវសេចក្តីថ្លែងការរួមគ្នា ឱ្យបានច្រើនតាមតែអាចធ្វើទៅបាន លើបញ្ហាដែលជាកង្វល់រួមគ្នា។ ប៉ុន្តែរាល់ការដាក់កំហិត ដូចជាការកំណត់ពេលវេលាសម្រាប់ភាគីបណ្តឹងរដ្ឋប្បវេណី/តំណាងផ្នែកច្បាប់ កាលពីពេលថ្មីៗនេះក្នុងសវនាការឧទ្ធរណ៍របស់ជនត្រូវចោទ និងមិនមានការកំណត់ពេលវេលាឱ្យបានស្មើគ្នាចំពោះភាគីផ្សេងៗទៀតគឺជាការរំលោភសិទ្ធិភាគីរដ្ឋប្បវេណី/តំណាងផ្នែកច្បាប់។

## VI. **សេចក្តីសន្និដ្ឋាន**

តាមច្បាប់អ.វ.ត.ក ក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុង ដែលនៅជាធរមាន ភាគីរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន។ ការដាក់កំហិតមិនឱ្យប្រើប្រាស់សិទ្ធិទាំងនេះត្រូវតែស៊ីសង្វាក់គ្នានឹងច្បាប់ដែលនៅជាធរមាន និងមិនត្រូវធ្វើឱ្យប៉ះពាល់សិទ្ធិរបស់ភាគីរដ្ឋប្បវេណីទេ។

**ដោយហេតុផលទាំងអស់នេះ**

**យើងខ្ញុំស្នើសុំឱ្យអង្គបុរេជំនុំជម្រះ**

បដិសេធន៍ការទាមទាររបស់មេធាវីការពារក្តី

មេធាវីដើមបណ្តឹងរដ្ឋប្បវេណី

មេធាវី ឡោ ជុនធី

មេធាវី នី ចាន់ឌី

មេធាវីរបស់ជំនួយផ្នែកច្បាប់នៃកម្ពុជា

ធ្វើនៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០០៨

ភ្នំពេញ